ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មានរួម
# នៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសលើកទី២ នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង
# ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា

១. កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ឡាងឆាងលើកទី២ ត្រូវបានប្រារព្ធឡើងនៅទីក្រុងសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦។ ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម វ៉ាង យី រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋប្រជាមានិតចិន ឯកឧត្តម សាលើមសៃ គុំម៉ាស៊ីត រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ឯកឧត្តម ក្យាវ ទីន អនុរដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ារ ឯកឧត្តម ដន ប្រាមុតវិណៃ រដ្ឋមន្ត្រីការបរទេសនៃព្រះរាជាណាចក្រថៃ ឯកឧត្តម ផាម ប៊ិញមិញ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានចូលរួមកិច្ចប្រជុំ។ រដ្ឋមន្ត្រីការបរទេសកម្ពុជា និងរដ្ឋមន្ត្រីការបរទេសចិន បានធ្វើជាសហប្រធាននៃកិច្ចប្រជុំ។

២. រដ្ឋមន្ត្រី បានផ្លាស់ប្តូរយោបល់គ្នាយ៉ាងស៊ីជម្រៅ និងបានឯកភាពជាឯកច្ឆន្ទ លើការអនុវត្តលទ្ធផលនៃកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាងលើកទី១ និងការជំរុញកិច្ចសហប្រតិបត្តិការឆ្ពោះទៅមុខ។

៣. រដ្ឋមន្ត្រីបានវាយតម្លៃខ្ពស់ ចំពោះភាពជោគជ័យនៃកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី១ នៅទីក្រុងសាន់យ៉ា ខេត្តហៃណាន ប្រទេសចិន កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ដែលបានដាក់អោយប្រើប្រាស់ជាផ្លូវការនូវយន្តការមេគង្គ-ឡានឆាង ដោយសម្រេចបានលទ្ធផលសំខាន់ៗ និងបានជំរុញអោយមានគំនិតផ្តួចផ្តើមនៃកិច្ចសហប្រតិបត្តិការជាច្រើន។ កិច្ចប្រជុំបានដាក់ចេញសេចក្តីថ្លែងការណ៍ទីក្រុងសាន់យ៉ា និងសេចក្តីប្រកាសរួម ស្តីពីកិច្ចសហប្រតិបត្តិការលើសមត្ថភាពផលិតនៃបណ្តាប្រទេសមេគង្គ-ឡានឆាង ព្រមទាំងបានអនុម័តបញ្ជីរួមនៃគម្រោងឆាប់ទទួលបានផលភ្លាមៗនៃ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដែលបង្កើតបានជាមូលដ្ឋានគ្រឹះដ៏រឹងមាំ សំរាប់ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

៤. ផ្អែកតាមការព្រមព្រៀងជាឯកច្ឆន្ទនៅក្នុងកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាងលើកទី១ រដ្ឋមន្ត្រីបានកត់សម្គាល់ប្រកបដោយសោមនស្សរីករាយ រចនាសម្ព័ន្ធនៃក្របខ័ណ្ឌពហុវិស័យ និងពហុកម្រិត ដែលរួមមានកិច្ចប្រជុំកំពូល កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស កិច្ចប្រជុំឧត្តមមន្ត្រី និងកិច្ចប្រជុំក្រុមការងារ ត្រូវបានបង្កើតឡើង។ ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ៣+៥ ដែលផ្អែកលើសសរស្តម្ភបីនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងវិស័យអាទិភាពគន្លឹះទាំងប្រាំ ត្រូវបានបង្កើតឡើងដោយផ្តោតលើការអភិវឌ្ឍសសរស្តម្ភទាំងបី រួមមានបញ្ហាសន្តិសុខ និងនយោបាយ ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងការផ្លាស់ប្តូរសង្គម វប្បធម៌ និងប្រជាជន-ប្រជាជន ជាមួយនឹងកិច្ចសហប្រតិបត្តិការជាក់ស្តែង លើវិស័យអាទិភាពគន្លឹះទាំងប្រាំ រួមមានការតភ្ជាប់ សមត្ថភាពផលិត កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងដែន ធនធានទឹក កសិកម្ម និងការកាត់បន្ថយភាពក្រីក្រ។

៥. ជាមួយនឹងការកត់សម្គាល់ដោយសេចក្តីពេញចិត្ត ចំពោះសកម្មភាពនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង រដ្ឋមន្ត្រីបានស្វាគមន៍ចំពោះការរីកចម្រើនគួរអោយកត់សម្គាល់ ក្នុងការអនុវត្តលទ្ធផលដែលបានសម្រេចនៅក្នុងកិច្ចប្រជុំកំពូលមេគង្គ-ឡាងឆាងលើកទី១ និងការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យជាច្រើន។ រដ្ឋមន្ត្រីបានពិនិត្យ និងអនុម័តបញ្ជីតាមដានលទ្ធផលនៃកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាងលើកទី១។

៦. រដ្ឋមន្ត្រីបានកត់សម្គាល់ថា ដំណើរការនៃការបង្កើតក្រុមការងាររួមលើវិស័យអាទិភាពគន្លឹះដូចជា ការតភ្ជាប់ សមត្ថភាពផលិត កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងដែន ធនធានទឹក កសិកម្ម និងការកាត់បន្ថយភាពក្រីក្រ បានចាប់ផ្តើម។

៧. រដ្ឋមន្ត្រីបានកត់សម្គាល់ដោយសេចក្តីរីករាយ ដែលគម្រោងឆាប់ទទួលបានផលភ្លាមៗ បាននឹងកំពុងអនុវត្តយ៉ាងសកម្ម ដោយគម្រោងមួយចំនួនត្រូវបានបញ្ចប់ និងការផ្លាស់ប្តូរគម្រោងកិច្ចសហប្រតិបត្តិការមួយចំនួនក្នុងវិស័យផ្សេងទៀតក៏ត្រូវបានអនុវត្ត និងសម្រេចបាននូវលទ្ធផលជាវិជ្ជមាន។ ទាំងនេះបង្ហាញយ៉ាងពេញលេញនូវប្រសិទ្ធភាព និងភាពជាក់ស្តែងនៃកិច្ចសហប្រតិបត្តិមេគង្គ-ឡានឆាង។

៨. រដ្ឋមន្ត្រីបានវាយតម្លៃខ្ពស់ចំពោះសំណើរបស់ចិន ក្នុងការបង្កើតមូលនិធិពិសេសនៃកិច្ចសហ-ប្រតិបត្តិការមេគង្គ-ឡានឆាង និងការផ្តល់នូវគាំទ្រហិរញ្ញវត្ថុផ្សេងៗ បានស្វាគមន៍ការចាប់ផ្តើមដំណើរការ

បែបបទមូលនិធិពិសេសនេះ និងសង្ឃឹមថាមូលនិធិនឹងដើរតួនាទីជាវិជ្ជមានក្នុងការជំរុញការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការជាមិត្តភាពដើម្បីផលប្រយោជន៍របស់ប្រជាជននៃប្រទេសទាំងប្រាំមួយ។

៩. រដ្ឋមន្ត្រីបានឯកភាពគ្នាពង្រឹងការធ្វើផែនការរយៈពេលវែង និងគំរូនៃការសម្រេចចិត្តពីថ្នាក់លើមកថ្នាក់ក្រោមនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ហើយបានប្រគល់ភារកិច្ចជូនឧត្តមមន្ត្រី និងក្រុមការងារ ដើម្បីរៀបចំបង្កើតផែនការសកម្មភាពរយៈពេលប្រាំឆ្នាំនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ក្នុងគោលដៅរក្សានូវការអភិវឌ្ឍប្រកបដោយចីរភាព និងភាពរឹងមាំខ្លាំងក្លានៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

១០. រដ្ឋមន្ត្រីបានអំពាវនាវឱ្យពង្រឹងការកសាងស្ថាប័នកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងគូសបញ្ជាក់ពីតម្រូវការសម្របសម្រួល និងតួនាទីចង្អុលបង្ហាញរបស់បណ្តាក្រសួងការបរទេសនៃបណ្តាប្រទេសមេគង្គ-ឡានឆាង។ រដ្ឋមន្ត្រីបានឯកភាពបង្កើតលេខាធិការដ្ឋានជាតិ/អង្គភាពសម្របសម្រួល នៅក្នុងក្រសួងការបរទេស ឬសមស្របទៅតាមស្ថានភាពរបស់ប្រទេសនីមួយៗ ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យឲ្យមានប្រសិទ្ធភាព ក្នុងន័យដើម្បីតាមដានការអនុវត្តគម្រោង និងធានានូវការរីកចម្រើនឥតឈប់ឈរនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

១១. រដ្ឋមន្ត្រីទាំងអស់បានពិនិត្យ និងអនុម័ត ឯកសារគោលការណ៍ទូទៅនៃការបង្កើតក្រុមការងាររួមលើវិស័យអាទិភាពគន្លឹះ ដើម្បីបង្កើតបទដ្ឋាននៃគោលដៅ សមាសភាព វិសាលភាពការងារ គំរូកិច្ចប្រជុំ និងខ្សែបណ្តោយរបាយការណ៍របស់ក្រុមការងាររួម និងសង្ឃឹមថាក្រុមការងាររួមមកពីស្ថាប័នពាក់ព័ន្ធដែលទទួលបន្ទុកវិស័យអាទិភាពគន្លឹះនៅក្នុងប្រទេសទាំងប្រាំមួយ នឹងត្រូវបង្កើត និងដំណើរការឆាប់ៗ ដោយយោងតាមឯកសារគោលការណ៍ដែលបានរៀបរាប់ខាងលើ។

១២. រដ្ឋមន្ត្រីលើកទឹកចិត្តឱ្យស្ថាប័នពាក់ព័ន្ធនៃប្រទេសនីមួយៗ ពង្រឹងការប្រាស្រ័យទាក់ទងការសម្របសម្រួល និងពិគ្រោះយោបល់ អនុវត្តគម្រោងឆាប់ទទួលបានផលភ្លាមៗ ដើម្បីជាប្រយោជន៍ដល់ប្រជាជន ហើយចាប់ផ្តើមដំណើរការប្រមូលគម្រោងឆាប់ទទួលបានផលភ្លាមៗដំណាក់កាលទីពីរ ដោយស្របទៅតាមគោលការណ៍ជ្រើសរើសគម្រោងឆាប់ទទួលបានផលភ្លាមៗក្នុងពេលឆាប់ៗ។

១៣. ជាមួយនឹងការរំលឹកនូវគោលការណ៍កុងសង់ស៊ីស សមភាព ការពិគ្រោះយោបល់ និងសម្របសម្រួលគ្នាទៅវិញទៅមក ការស្ម័គ្រចិត្ត ការចូលរួមចំណែកជាមួយគ្នា និងការចែករំលែកផលប្រយោជន៍ និងការគោរពតាមធម្មនុញ្ញអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិនានា បានអះអាងសារជាថ្មីថា

កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងគួរគោរពតាមស្មារតីនៃភាពបើកចំហរ និងការរួមបញ្ចូលគ្នា ដែលស្របទៅនឹងវិស័យអាទិភាពនានានៃការកសាងសហគមន៍អាស៊ាន និងកិច្ចសហប្រតិបត្តិការអាស៊ាន-ចិន ព្រមទាំងបំពេញបន្ថែមនិងអភិវឌ្ឍស្របជាមួយនឹងយន្តការសហប្រតិបត្តិការអនុតំបន់ទន្លេមេគង្គដែលមានស្រាប់។

១៤. រដ្ឋមន្ត្រីបានសង្កត់ធ្ងន់ ភាគីទាំងអស់គួរជំរុញបន្ថែមទៀតនូវការអនុវត្តលទ្ធផលនៃកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាង និងធ្វើការឆ្ពោះទៅរកសហគមន៍រួមអនាគតគ្នាប្រកបដោយសន្តិភាព និងវិបុលភាព ស្ថិតក្នុងក្របខណ្ឌដែលរួមបញ្ចូលនូវមគ្គុទេសន៍របស់ប្រមុខដឹកនាំ កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ការចូលរួមយ៉ាងទូលំទូលាយ ដោយឈរលើការតម្រង់ទិសរបស់រដ្ឋាភិបាល ការចូលរួមចម្រុះ និងគម្រោងតម្រង់ទិសគំរូ។

១៥. រដ្ឋមន្ត្រីបានថ្លែងអំណរគុណដល់ប្រទេសកម្ពុជាដែលជាម្ចាស់ផ្ទះ ចំពោះបដិសណ្ឋារកិច្ចជូនដល់គណៈប្រតិភូទាំងអស់ និងការរៀបចំកិច្ចប្រជុំនេះយ៉ាងយកចិត្តទុកដាក់។